អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលធនធាន និងប្រកាសផ្សព្វផ្សាយវីដេអូខ្លីអប់រំ ជាស៊េរី

**ភ្នំពេញ ប្រទេសកម្ពុជា** – អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) នៅថ្ងៃនេះ បានបើកសម្ពោធមជ្ឈមណ្ឌលធនធានជាផ្លូវការដែលមានទីតាំងនៅអគារថ្មីរបស់ខ្លួន។ មជ្ឈមណ្ឌលធនធាន នេះ គឺជាចំណុចស្នូលនៃកេរដំណែលរបស់ អ.វ.ត.ក. និងជាមជ្ឈមណ្ឌលសម្រាប់សាធារណជនក្នុងការសិក្សាស្រាវជ្រាវនិងស្វែងរកព័ត៌មាន បន្ទាប់ពីការបញ្ចប់ដំណើរការនីតិវិធីតុលាការ។ ពិធីសម្ពោធនេះ ក៏ប្រកាសដាក់ឲ្យដំណើរការផ្សព្វផ្សាយវីដេអូខ្លីអប់រំ ជាស៊េរី ដើម្បីផ្សព្វផ្សាយអំពីការងាររបស់ អ.វ.ត.ក.។

ឯកឧត្តម **ក្រាញ់ តូនី** ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. មានប្រសាសន៍ថា៖ «អ.វ.ត.ក. មានមោទនភាពក្នុងការសម្ពោធមជ្ឈមណ្ឌលធនធាន និងប្រកាសផ្សព្វផ្សាយនូវវីដេអូខ្លីអប់រំ ជាស៊េរី»។ លោកមានប្រសាសន៍បន្ថែមទៀតថា៖ ការបង្កើតមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. គឺឆ្លើយតបទៅនឹងតម្រូវការក្នុងការអនុវត្តការងារផ្សព្វផ្សាយនិងអប់រំ ពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះក្តី និងការងារគ្រប់គ្រងបណ្ណសារឲ្យបានទូលំទូលាយដល់សាធារណជន និង តាមដានការអនុវត្តគម្រោងនានាដែលបានសម្រេចផ្តល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះនៃរបបខ្មែរក្រហម។

ពិធីនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារទទួលបន្ទុកការអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក.។

**ឯកឧត្តម វង្សី វិស្សុត** មានប្រសាសន៍ថា៖ «ក្នុងការអនុវត្តមុខងារសេសសល់ឲ្យបានទទួលជោគជ័យនាពេលខាងមុខ រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ បានបន្តផ្តល់ការគាំទ្រដល់អ.វ.ត.ក. ជាពិសេសការផ្សព្វផ្សាយព័ត៌មានអំពីបណ្ណសារនៃសំណុំរឿង និងដំណើរការជំនុំជម្រះក្តីរបស់អ.វ.ត.ក. ឲ្យបានទូលំទូលាយដល់សាធារណជន សិស្សនិស្សិត និងអ្នកស្រាវជ្រាវជាតិអន្តរជាតិ តាមរយៈការបង្កើតមជ្ឈមណ្ឌលធនធាននេះ ដែលជាផ្នែកស្នូលនៃការងារផ្សព្វផ្សាយនិងការលើកកម្ពស់ដល់កេរដំណែលរបស់អ.វ.ត.ក.»។ **ឯកឧត្តម** មានប្រសាសន៍បន្ថែមទៀតថា៖ «មជ្ឈមណ្ឌលធនធាននេះ មានសមាសភាគសំខាន់ៗ ចំនួន៦ ដែលរួមមាន៖ (ទី១) បណ្ណាល័យនិងកន្លែងស្រាវជ្រាវ (ទី២) គេហទំព័រថ្មីដែលកំពុងកែលម្អនិងធ្វើបច្ចុប្បន្នភាពប្រកបដោយភាពច្នៃប្រឌិត (ទី៣) និហិតដ្ឋានបណ្ណសារ (ទី៤) បន្ទប់ប្រើប្រាស់ពហុបំណងសម្រាប់រៀបចំសិក្ខាសាលា និងតុលាការនិម្មិត (ទី៥) បន្ទប់ពិគ្រោះយោបល់ និងតាំងពិព័រណ៍ និង (ទី៦) ឧទ្យានសម្រាប់ការចងចាំ»។

សហប្រធាននៃក្រុមមិត្តអ.វ.ត.ក. រួមមាន **ឯកឧត្តម អ៊ូ អ៊ិណុ អាត់ស៊ូស៊ី** ឯកអគ្គរដ្ឋទូតជប៉ុន **ឯកឧត្តម Jacques PELLET** ឯកអគ្គរដ្ឋទូតបារាំង **ឯកឧត្តម Joseph SCHEUER** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា

អគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ២៣ ៨៦១ ៥៥៥
Building 40, Russian Federation Blvd. (110), Sangkat Mittapheap, Khan 7 Makara, Phnom Penh, Cambodia. P.O. BOX 71
Bâtiment 40, Fédération de Russie Blvd. (110), Sangkat Mittapheap, Khan 7 Makara, Phnom Penh, Cambodia. P.O. BOX 71
TEL: +855 (0) 23 861 500 | Fax: +855 (0) 23 861 555 | www.eccc.gov.kh

ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋកូរ៉េខាងត្បូង និងមិត្តភក្តិ រួមទាំងសមាជិកដៃគូអនុវត្តដទៃទៀត ក៏មានវត្តមាននៅក្នុងពិធីនេះផងដែរ។

ក្នុងឱកាសនៃពិធីនេះដែរ អ.វ.ត.ក. ក៏ប្រកាសដាក់ឲ្យដំណើរការផ្សព្វផ្សាយកម្មវិធីវីដេអូខ្លីអប់រំ ជាស៊េរី ដែលខ្លឹមសារនៃវីដេអូអប់រំនេះ គឺដកស្រង់ចេញពីឯកសារ កំណត់ត្រា និងបណ្ណសារ ដែលរំលេចនូវប្រធានបទជាច្រើនទាក់ទងនឹងការជំនុំជម្រះក្តី និងការស៊ើបអង្កេតក្តីក្នុងរយៈពេល១៦ឆ្នាំ។ វីដេអូអប់រំខ្លីជាស៊េរី នឹងក្លាយជាផ្នែកសំខាន់មួយនៃសកម្មភាពអប់រំ ក្នុងគោលបំណងផ្សព្វផ្សាយអំពីការងាររបស់អ.វ.ត.ក. សម្រាប់យុវជនជំនាន់ក្រោយ។ វគ្គដំបូងនៃវីដេអូខ្លីអប់រំ ជាស៊េរី នេះ ត្រូវបានចេញផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់របស់អ.វ.ត.ក. រួមមានទំព័រហ្វេសប៊ុក យូធូប តេឡេក្រាម និង បណ្តាញសង្គមតីតុក។

មជ្ឈមណ្ឌលធនធាន មានទីតាំងនៅក្នុងបរិវេណការិយាល័យថ្មីរបស់អ.វ.ត.ក. អគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី (ផ្លូវ១១០) សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ។ បណ្ណាល័យ និងកន្លែងស្រាវជ្រាវ នៃមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. នឹងបើកដំណើរជាសាធារណៈចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ ហើយបើកជារៀងរាល់ថ្ងៃ (ច័ន្ទដល់សុក្រ) ពីម៉ោង ១០:០០ ដល់ ២០:០០ និង នៅចុងសប្តាហ៍ និងថ្ងៃបុណ្យឈប់សម្រាកបើកពីម៉ោង១០:០០ ដល់ ១៨:០០។ ការចូលប្រើប្រាស់មជ្ឈមណ្ឌលធនធាននេះគឺ មិនគិតថ្លៃនោះទេ។

###

**កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន៖**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) គឺជាស្ថាប័នតុលាការក្នុងស្រុកមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ប្រទេសកម្ពុជា។ អ.វ.ត.ក. មានយុត្តាធិការក្នុងជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ នៃក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងកំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

បន្ទាប់ពីបញ្ចប់ដំណើរការកាត់ក្តីរបស់ខ្លួន អ.វ.ត.ក.បានចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៣ ដើម្បីអនុវត្តលើមុខងារដែលនៅសល់សម្រាប់រយៈពេលបីឆ្នាំដំបូង។ ផ្នែកសំខាន់មួយ នៃមុខងារដែលនៅសេសសល់ទាំងនេះ គឺការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទាក់ទងនឹងការងាររបស់អ.វ.ត.ក.។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**


**លោក គុណ ចិន្តា**
**មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ**
**លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧**
**អ៊ីម៉ែល៖** kun.chenda@eccc.gov.kh


**សម្រាប់ព័ត៌មានបន្ថែមទៀត៖**

- ផែនទីអាសយដ្ឋានទីតាំងនៃមជ្ឈមណ្ឌលធនធាន ៖ https://maps.app.goo.gl/wPYSyLq5Q9txFqu97
- ការបោះពុម្ពផ្សាយរបស់ អ.វ.ត.ក. ៖ https://eccc.gov.kh/en/public-affair/publication